# លាភូមិកំណើត

លំនាំបទៈ  ដាក់ទុនស្នេហ៍អូន

១.  ជីវិតអភ័ព្វធ្លាប់តែជួបជុំ  ពេលនេះរូបខ្ញុំត្រូវឃ្លាតឆ្ងាយពីអ្នកម្ដាយ
ឃ្លាតទាំងឪពុកអ្នកភូមិទាំងឡាយ  លាមីងមាបងប្អូនជិតឆ្ងាយ  ផ្ញើកាយទៅនៅស្រុកគេ ។

២.  ពេលដែលចាកចេញទន្ទេញគ្មានភ្លេច  ទោះឃ្លាតឆ្ងាយពិតក៏ចិត្តនៅនឹកភូមិឋាន
នឹកអើយនឹកស្រុកគ្មានពេលស្រាកស្រាន្ត  ទោះដឹងថាមិនងាយវិលថ្កានក៏ប្រាណនៅតែសង្ឃឹម ។

បន្ទរ  ឱ!ភូមិកំណើតខ្ញុំព្រាត់ពីអ្នក  ចិត្តអួលអាក់កើតទុក្ខក្នុងទ្រូងឥតស្បើយ
មានតែទឹកភ្នែកដែលជាចម្លើយ  ថាខ្ញុំត្រូវស្ដើយចិត្តអើយនឹកណាស់ ។

៣.  ខ្ញុំលើកដៃលាមិត្តនៅសាលា  ធ្លាប់រួមសិក្សាលាគ្រូលាមិត្តរួមថ្នាក់
ខ្ញុំត្រូវចេញធ្វើការរោងចក្រ  នៅទីក្រុងដើម្បីរកប្រាក់  ឆ្ងាយអ្នកទាំងក្ដីអាល័យ ។

បន្ទរ  ពេលជិះក្នុងឡានកល្យាណរំពៃ  វាលស្រែស្ងួតថ្មីតែដីប្រេះបែកក្រហែង
ឆ្នាំមុនទឹកជន់ទ្រូងសែនចំបែង  ឆ្នាំនេះហួតហែងស្រូវស្កកគ្មានសល់ ។

៤.  មកដល់ទីក្រុងស្លុងស្លុតអារម្មណ៍  អស់ឱ!  ខ្លួនខ្ញុំត្រូវគិតធ្វើយ៉ាងណា
ខ្វីលុយគេសូកចូលធ្វើការ  បានប្រាក់ខែសងគេឆាប់រ៉ា  អនិច្ចាវាសនា  ខ្ញុំអើយ ។

អង្គការស្ត្រីដើម្បីការផ្លាស់ប្ដូរ
កម្មវិធីកម្មកររោងចក្រកាត់ដេរ ©២០០៥

និពន្ធនិងច្រៀងដោយកម្មកររោងចក្រកាត់ដេរ